សកម្មភាព ៖ **ទម្លាប់អនាម័យល្អ និងមិនល្អ**

**វិទ្យាសាស្ត្រ** បំណិនអនាម័យ (ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

**សិក្សាសង្គម** ការយល់ដឹងអំពីខ្លួនឯង (ស្គាល់ពីអារម្មណ៍មួយចំនួន),

(សម្តែងអារម្មណ៍និងចេះសង្កត់ចិត្តរបស់ខ្លួន)

**គោលបំណង** ៖

**(វិទ្យាសាស្ត្រ)** ប្រាប់ពីទម្លាប់ល្អទាំងឡាយ មុន និងក្រោយពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត ចូលបង្គន់អនាម័យ សម្អាតខ្លួនប្រាណ ។

ប្រាប់ពីការប្រុងប្រយ័ត្នពេលក្អក កណ្តាស់ និងសម្អាតច្រមុះពេលហៀរសំបោរ។

**(សិក្សាសង្គម)** ប្រាប់បានពីអារម្មណ៍ ឬឥរិយាបថនៃការព្រួយបារម្មណ៍ កង្វល់ក្នុងព្រឹត្តិការណ៍មួយចំនួន។

ប្រាប់បានពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយការធ្វើកាយវិការ ទឹកមុខ និងពាក្យសម្តី។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "បិសាចចម្លែកតូចៗ" ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០នាទី

**ឧបករណ៍** ៖ សៀវភៅរឿង បិសាចចម្លែកតូច ,កាតទឹកមុខសប្បាយរីករាយ (សខ្មៅ, ពណ៌) និងទឹកមុខសោកសៅ (សខ្មៅ, ពណ៌), (រូបភាពទម្លាប់អនាម័យល្អ និងមិនល្អ)។

**ការរៀបចំ** ៖ ការរៀបចំសម្ភារគឺធ្វើតាមការជ្រើសរើសមធ្យោបាយលេង។

-ស្វែងរក ឬ បោះពុម្ពចេញរូបភាពទម្លាប់អនាម័យល្អ និងមិនល្អដោយខ្លួនឯងសម្រាប់បិទលើក្តាខៀន ឬ ជញ្ជាំងថ្នាក់។

-បោះពុម្ពទឹកមុខសប្បាយរីករាយ និងទឹកមុខសោកសៅសម្រាប់បិទនៅលើជញ្ជាំង ក្តារខៀនជាដើម។

-បោះពុម្ពចេញរូបភាពទម្លាប់អនាម័យល្អ និងមិនល្អសម្រាប់កាត់ដាក់ក្នុងថុងក៏បាន។

-សរសេរជាអក្សរអំពីទម្លាប់អនាម័យល្អ និងមិនល្អ(សរសេរតាមចំនួនក្មេង ឬ អាចសរសេរដដែលក៏បានដែរ)ដាក់ក្នុងប្រអប់។

-នៅពេលក្មេងចាប់អាចឱ្យលោកគ្រូ អ្នកគ្រូអានស្ងាត់ៗឱ្យក្មេងស្តាប់ម្នាក់ម្តង ក៏បានដែរ។

-បង្កើតជាប្រអប់ ឬ ថុងសម្រាប់ក្មេងលូកដៃយកក្រដាសចេញ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះលោកគ្រូ អ្នកគ្រូនឹងអានសៀវភៅរឿង "បិសាចចម្លែកតូចៗ" ឱ្យកូនៗទាំងអស់គ្នាស្តាប់។
2. អ្នកគ្រូនឹងលេងល្បែងទម្លាប់អនាម័យល្អ និងមិនល្អជាមួយកូនៗទាំងអស់គ្នា។
3. សរសេរពាក្យ "អនាម័យ" នៅលើក្តារខៀន ។

4. សួរក្មេង៖ តើកូនៗធ្លាប់លឺពាក្យ “អនាម័យ” ដែរឬទេ? បាទ/ចាស ធ្លាប់លឺ។
5. ចូរកូនៗនិយាយពីទម្លាប់អនាម័យល្អឱ្យអ្នកគ្រូស្តាប់បន្តិចមើល? ចុះទម្លាប់ទម្លាប់អនាម័យមិនល្អវិញ? សរសេរចម្លើយដាក់លើក្តាខៀន។
6. បង្ហាញទឹកមុខញញឹមដំណាងឱ្យទម្លាប់អនាម័យល្អ និងទឹកមុខសោកសៅដំណាងឱ្យទម្លាប់អនាម័យមិនល្អ។

**បំរែបំរួល៖**

**របៀបលេងមាន ៥របៀបអាស្រ័យតាមការសម្រេចចិត្តរបស់លោកគ្រូ អ្នកគ្រូ។**

1. ឧទាហរណ៍៖ តើមិនដុសធ្មេងជាអនាម័យមិនល្អ ឬ អនាម័យល្អ? (ឱ្យក្មេងៗនៅអង្គុយកន្លែងធម្មតា) សូមកូនៗទាំងអស់គ្នាលើកដៃ បើគិតថាមិនដុសធ្មេញជាអនាម័យមិនល្អ។
2. សួរសំណួរអនាម័យល្អ និងមិនល្អជាមួយក្មេងៗម្នាក់ម្តងរួចឱ្យក្មេងធ្វើទឹកមុខតាមការគិតឃើញរបស់ក្មេង។ បើកូនៗគិតថាមិនមានអនាម័យល្អ សូមកូនៗធ្វើទឹកមុខសោកសៅ។ បើកូនៗគិតថាមានអនាម័យល្អ សូមកូនៗធ្វើទឹកមុខសប្បាយរីករាយ ។
3. ម្យ៉ាងវិញទៀតលោកគ្រូ អ្នកគ្រូអាចសួរម្នាក់ម្តងឱ្យកូនៗឆ្លើយក៏បាន(សំណួរអំពីរអនាម័យផ្សេងៗគ្នាតាមពេលវេលា)។
4. លេងជាពីរក្រុមអនាម័យល្អ ម្ខាងទៀតអនាម័យមិនល្អ ឬ បិទទឹកមុខសប្បាយរីករាយ និងទឹកមុខសោកសៅបន្ទាប់មកឱ្យកូនៗឈរនៅមុខក្តារខៀនទាំងអស់គ្នា ហើយសួរម្នាក់ម្តងៗរួចឱក្មេងៗជ្រើសរើសទៅអង្គុយកៅអីដោយខ្លួនឯង។ ឧទាហរណ៍៖ តើកូនៗមិនដុសធ្មេញជាអនាម័យល្អ ឬ មិនល្អ? តើកូនៗគួរទៅអង្គុយកៅអីខាងណា?ទឹកមុខសប្បាយរីករាយ ឬក៏ទឹកមុខសោកសៅ។ ចាស/បាទ៖ កៅអីទឹកមុខសប្បាយរីករាយ ឬ ទឹកមុខសោកសៅ។ (ប្រើសំណួរអំពីរអនាម័យផ្សេងៗគ្នាតាមពេលវេលា)
5. បិទរូបទឹកមុខសប្បាយរីករាយណាងឱ្យអនាម័យល្អ រូបទឹកមុខសោកសៅតំណាងឱ្យអនាម័យមិនល្អលើក្តារខៀន។ ធ្វើបែបនេះមានពីររបៀប៖
   ១.របៀបទីមួយសរសេរសំណួរអំពីអនាម័យល្អ និងអនាម័យមិនល្អដាក់ក្នុងប្រអប់ឱ្យក្មេងៗលូកចាប់ម្នាក់ម្តង បន្ទាប់មកអ្នកគ្រូវអានឱ្យក្មេងៗស្តាប់ម្នាក់ម្តងដោយខ្សឹបៗ។ ឱ្យក្មេងៗគិត តើកូនៗគួរទៅឈរនៅពីមុខទឹកមុខសោកសៅ ឬទឹកមុខសប្បាយរីករាយ? ក្រោយពីក្មេងឈរបានត្រឹមត្រូវហើយ ត្រូវឱ្យគាត់ពិពណ៌នាសារឡើងវិញ។
   ឧទាហរណ៍៖ មិត្តដឹងទេមិនដុសធ្មេញគឺអនាម័យមិនល្អមានទឹកមុខសោកសៅ ។
   ២.របៀបទីពីរប្រើរូបភាពអនាម័យល្អ និងអនាម័យមិនល្អដាក់ក្នុងប្រអប់ឱ្យក្មេងៗលូកចាប់ម្នាក់ម្តង ។ រួចឱ្យក្មេងៗគិតដោយខ្លួនឯង តើគួរទៅឈរនៅពីមុខទឹកមុខសោកសៅ ឬ ទឹកមុខសប្បាយរីករាយ?

ឧទាហរណ៍ទម្លាប់អនាម័យល្អ និងមិនល្អ៖

| ទម្លាប់អនាម័យល្អ | ទម្លាប់អនាម័យមិនល្អ |
|---|---|
| លាងដៃរបស់អ្នកមុននឹងហូបចំណី | មិនលាងដៃរបស់អ្នកមុននឹងហូបចំណី |
| លាងសម្អាត់ដៃរបស់ដោយប្រើសាប៊ូ | លាងសម្អាត់ដៃរបស់ដោយមិនប្រើសាប៊ូ |
| លាងដៃក្រោយចេញពីបន្ទប់ទឹក | មិនលាងដៃក្រោយចេញពីបន្ទប់ទឹក |
| ញ៉ាំទឹកស្អាត | ញ៉ាំទឹកមិនស្អាត |
| ហូបផ្លែឈើដោយលាងសម្អាតមុន | ហូបផ្លែឈើដោយមិនបានលាងសម្អាត |
| ដុសធ្មេញរបស់អ្នកក្រោយហូបចំណី | មិនដុសធ្មេញរបស់អ្នកក្រោយហូបចំណី |
| ងូតទឹកដុសសាប៊ូ | ងូតទឹកមិនដុសសាប៊ូ |
| ចូលដេកងូតទឹក | ចូលដេកមិនងូតទឹក |
| ដាក់សម្រាមនៅក្នុងធុងសម្រាម | ចោលសម្រាមនៅលើផ្លូវ |
| សម្អាត និងរៀបចំបន្ទប់ | មិនសម្អាត និងមិនរៀបចំបន្ទប់ |
| ខ្ទប់មាត់នៅពេលក្អក ឬ កណ្តាស់ | មិនខ្ទប់មាត់នៅពេលក្អក ឬ កណ្តាស់ |
| សម្អាតច្រមុះពេលហៀរសំបោរ | មិនសម្អាតច្រមុះពេលហៀរសំបោរ |